# "ចាក់ចេក" សិល្បៈក្បាច់រចនាដែលកាន់តែហោចទៅ

ចាក់ចេក ឬចាក់ក្បាច់[១] ជាក្បាច់រចនានៅលើស្រទបចេក ហើយប្រើក្រដាសពណ៌ដើម្បីរំលេចផ្ទៃក្បាច់ឱ្យលេចឃើញច្បាស់ស្រស់ល្អសមភ្នែក។ ជួនកាលគេប្រើល័ក្តពណ៌ជ្រលក់គូរបន្ថែមលើនោះទៀត ដើម្បីឱ្យក្បាច់កាន់តែលេចច្បាស់ឡើង។ ក្នុងសង្គមខ្មែរ ការប្រើក្បាច់ចាក់ចេកមានទាំងក្នុងព្រះរាជពិធី ពិធីសម្រាប់ព្រះសង្ឃមានកិត្តយសខ្ពង់ខ្ពស់ និងពិធីប្រពៃណីអ្នកស្រុក។ ចំពោះអ្នកស្រុកតំបន់អង្គរ ចាក់ចេកហាក់ដូចជាសិល្បៈយ៉ាងសំខាន់ស្ទើរខ្វះពុំបាន ដ្បិតក្រៅពីរៀបចំគ្រឿងរណ្តាប់សក្ការៈដូចជា បាយសី និងស្លាធម៌ជាដើម គេតែងចាត់ចែងចាក់ចេកតុបតែងឱ្យបានសមរម្យតាមពិធីផ្សេងៗ។

តាមទំនៀមនិងទម្លាប់តមក គេប្រើក្បាច់ចាក់ចេកតែនៅលើទីសក្ការៈផ្សេងៗនៃពិធីដូចជា លម្អលើអាសនៈតម្កល់ព្រះបដិមា បុស្បុកស្រោចទឹក បុស្បុកតម្កល់ព្រះពុទ្ធរូប ឬទេពផ្សេងៗ កន្ទ្រៃងតម្កល់គម្ពីរធម៌អាថ៌ កន្ទ្រៃងតម្កល់សព ភ្នំយោង ឬមេរុបូជាសព ។ល។ ក្នុងព្រះរាជពិធីតម្កល់ និងថ្វាយព្រះភ្លើងព្រះបរមសពអតីតព្រះមហាក្សត្រខ្មែរ គេតែងសង្កេតឃើញមានក្បាច់ចាក់ចេកលម្អជើងថ្កុរបុស្បុក និងកន្ទ្រៃងសក្ការៈផ្សេងៗជាដរាប។ ទិដ្ឋភាពនេះ មានជាប់ជាហូរហែតាមទំនៀម ដែលឃើញរហូតមកដល់ព្រះរាជពិធីតម្កល់ និងថ្វាយព្រះភ្លើងព្រះបរមសពព្រះបរមរតនកោដ្ឋ[២] (រូបលេខ១)។

ចំណែកពិធីថ្វាយព្រះភ្លើងព្រះសពសម្តេចព្រះធម្មលិខិត ព្រះសង្ឃនាយករងទី១ ក៏ប្រើក្បាច់ចាក់ចេកតុបតែងលម្អដែរ។ រីឯការប្រើក្បាច់ចាក់ចេកក្នុងកិច្ចពិធីរបស់ប្រជារាស្ត្រទូទៅ គេឃើញមានក្នុងពិធីបុណ្យសព បុណ្យពុទ្ធាភិសេក បុណ្យទេសន៍មហាជាតក៏ បុណ្យចម្រើនអាយុ ពិធីកោរជុក និងពិធីចេញម្លប់ជាដើម (រូបលេខ២-៣)។ ជាទូទៅនៅក្នុងព្រះរាជពិធី និងពិធីដូចរៀបរាប់ខាងលើ គេប្រើក្បាច់ចាក់ចេកសម្រាប់លម្អលើផ្នែក ឬវត្ថុសំខាន់ជាសក្ការៈនៃព្រះរាជពិធី និងពិធីនោះដូចជា អាសនៈពុទ្ធបូជា ពានពុទ្ធគុណ ពានទិស បុស្បុក គ្រែទេសន៍ ឬកន្ទ្រៃងតម្កល់ម្ឈូសសម្រាប់ពិធីបូជាភ្លើង ។ល។

---

[១] អ្នកស្រុកប៉ែកខាងជើងច្រើនហៅ "ចាក់ចេក" តែប៉ែកខាងត្បូងខ្លះហៅ "ចាក់ក្បាច់"។

[២] ព្រាប ចាន់ម៉ារ៉ា, គង់ វីរៈ, ជី វដ្ឋា ២០១៣: ៥៤

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត



រូបលេខ១ ក្បាច់ចាក់ចេកលម្អជើងថ្ករ និងបុស្បុកតម្កល់ព្រះសពព្រះបរមរតនកោដ្ឋ (រូប៖ ព្រាប ចាន់ម៉ារ៉ា)



រូបលេខ២-៣ ក្បាច់ចាក់ចេកលម្អព្រះឆាយាល័ក្ខណ៍ និងជើងថ្ករក្នុងពិធីថ្វាយព្រះភ្លើង សម្ដេចព្រះសង្ឃនាយករង់ទី១ (រូប៖ ?)

ដោយឡែក រូបខាងក្រោមជាការប្រើប្រាស់ក្បាច់ចាក់ចេក ក្នុងពិធីបុណ្យសពរបស់អ្នកស្រុកជនបទ (រូបលេខ៤-៥)។ តាមការសង្កេត ទម្រង់ក្បាច់ចាក់ចេកនេះមានលក្ខណៈពិសេសដោយឡែកមួយផ្សេងទៀត ក្នុងរបៀបជាទឹកដៃសិល្បៈរបស់អ្នកស្រុក។ ប៉ុន្តែបើពិនិត្យជារួម គេឃើញថាការលម្អលើសសរ គេប្រើទម្រង់ក្បាច់ចង្វាយស្រដៀងនឹងក្បាច់

លម្អលើសសរបុស្បុកក្នុងព្រះរាជពិធីដែរ។ រីឯទម្រង់ក្បាច់ដែលប្រើលើរបា គេប្រើក្បាច់មួយផ្សេងទៀត ហើយរំលេចដោយក្រដាសពណ៌ដូចគ្នា។




*រូបលេខ៤-៥ ការប្រើប្រាស់ក្បាច់ចាក់ចេកលម្អលើមេរុ ទីរំលាយសពរបស់អ្នកស្រុកជនបទ*

ខាងក្រោមនេះ ជាការប្រើក្បាច់ចាក់ចេកក្នុងពិធីបុណ្យពុទ្ធាភិសេក (រូបលេខ៦)។ ផ្នែកសំខាន់ដែលគេត្រូវប្រើ គឺកន្លែងតម្កល់ព្រះពុទ្ធរូបថ្មីធ្វើពិធីបើកព្រះនេត្រ។ ក្បាច់ត្រូវប្រើមានច្រើនកន្លែងណាស់ ពោលគឺរាប់តាំងពីសសរ របា និងហោជាងជាដើម។ នៅផ្នែខាងក្រោយ គេចងព្រះបត់ក្នុងចន្លោះក្បាច់ទាំងនោះទៀតផង។ ចំណែករូបលេខ៧ ក៏ជាការប្រើក្បាច់ចាក់ចេកក្នុងពិធីបុណ្យអភិសេកមួយផ្សេងទៀត តាមទំនៀមអ្នកស្រុកដែរ។ ការលម្អកន្លែងសក្ការៈក្នុងបុណ្យនេះ ក៏ពុំសូវខុសពីរូបលេខ៦។

សូមបញ្ជាក់ថា ការរៀបចំតុបតែងកន្លែងសក្ការៈក្នុងពិធីបុណ្យអភិសេកក្នុងរូបទាំងនេះ គេត្រូវការពេលស្ទើរពេញមួយថ្ងៃ ហើយតែងមានការចូលរួមជួយដៃដើងពីអ្នកជិតខាងជានិច្ច។ ចំពោះរូបលេខ៦ ដោយសារវេលាត្រូវថ្វាយបង្គំព្រះរតនត្រៃយ៍មកដល់ គេក៏ពុំទាន់រៀបចំស្រេចបាច់នៅឡើយ លុះចប់កិច្ចនេះទើបគេយកតុបតែងបន្ថែមផ្កាភ្ញី។




*រូបលេខ៦-៧ ក្បាច់ចាក់ចេកតុបតែងលម្អលើផ្នែកសំខាន់ៗនៃពុទ្ធាសនៈក្នុងពិធីបុណ្យពុទ្ធាភិសេក*

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

នៅវត្តអធ្វារ ខេត្តសៀមរាប គេតែងធ្វើបុណ្យឡើងអ្នកតា "ទួលតាមឿង" ដែលជាបុណ្យប្រពៃណីប្រចាំឆ្នាំ។ ក្នុងពិធីបុណ្យនោះ មានកន្លែងសក្ការៈសំខាន់ពីរដែលគេលម្អក្បាច់ចាក់ចេក។ មួយកន្លែង គឺទីអស្នាព្រះ ដែលស្ថិតនៅក្នុងរោងបុណ្យ (រូបលេខ៨) និងមួយកន្លែងទៀត គឺរានយមរាជ ឬនឹមរាជ (រូបលេខ៩) ដែលស្ថិតនៅជ្រុងឦសាននៃរោងបុណ្យ។ ទីសំខាន់ទាំងពីរ សុទ្ធតែប្រើក្បាច់ចាក់ចេកលម្អទាំងអស់ ហើយបើពិនិត្យសន្ទឹកក្បាច់វិញសោត គឺមានភាពពិសេស និងដោយឡែកផ្សេងមួយទៀតពីទម្រង់សន្ទឹកក្បាច់ដែលលើកមកបង្ហាញអម្បាលម៉ានខាងលើ។ សន្ទឹកក្បាច់នៅទីនេះ ហាក់ដូចជាមានលក្ខណៈតូចស្តើង តែមានប្រើក្រដាសពណ៌ដើម្បីរំលេចផ្ទៃក្បាច់ដូចគ្នា។




រូបលេខ៨ ក្បាច់ចាក់ចេកលម្អលើអស្នាព្រះ      រូបលេខ៩ ក្បាច់ចាក់ចេកលម្អលើរានយមរាជ

រីឯរូបខាងក្រោម គឺជាការប្រើក្បាច់ចាក់ចេកលម្អបុស្បុករានម៉ាក្នុងពិធីកោរជុកក្នុងខេត្តសៀមរាប (រូបលេខ១០-១១)។ តាមការសង្កេត ចំពោះក្បាច់លម្អនៅទីនេះមានពីរប្រភេទ គឺលម្អលើសសរ និងលើរបា។ ក្បាច់លម្អលើសសរ គឺមានលក្ខណៈជាចង្វាយចេញពីគល់សសរឡើងទៅលើ។ ក្បាច់លម្អលើរបាលើក្រោម មានលក្ខណៈដូចច្រវ៉ាក់ភ្ជាប់គ្នាពីមួយទៅមួយក្នុងរៀបជាសិល្បៈ។ សូមរំឭកដែរថា ក្នុងគំនិតខ្មែរចាត់ទុករានម៉ាដែលតុបតែងយ៉ាងវិចិត្រនេះជាភ្នំកៃលាស ហើយក្នុងកិច្ចផ្កាប់ជុក តែងមានព្រះសង្ឃធ្វើកិច្ចនៅលើនេះ។

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត



រូបលេខ១០ ចាក់ចេកលម្អបុស្បុកពានម៉ាកោរជុក



រូបលេខ១១ ចាក់ចេកលម្អពានម៉ាក្នុងពិធីកោរជុក

តាមការសង្កេត ចាក់ចេកជាសិល្បៈដែលមានលក្ខណៈពិសេសរៀងខ្លួនតាមតំបន់ តែជាទូទៅបច្ចេកទេសចាក់ចេក និងប្រភេទដើមចេកដែលប្រើហាក់ពុំខុសគ្នាឡើយ គឺគេនិយមប្រើចេកជ្វា ចេកស្អាប់មុខ និងចេកណាំវ៉ា ដ្បិតវាមានលក្ខណៈស្វិត មិនស្រួយ និងមិនធាប់ជាំ ឬស្មោក។ ប៉ុន្តែគ្រប់ប្រភេទដើមចេកដែលត្រូវយកមកចាក់ចេក គឺត្រូវតែជាដើមល្អ ស្រទបល្អ មិនស្មោក ឬជាំ និងនៅស្រស់ល្អ (រូបលេខ១២-១៣)។





រូបលេខ១២-១៣ ដើមចេកដែលគេយកមកចាក់ចេក

អ្នកចាក់ចេកទាមទារឱ្យមានចិត្តអំណត់ រីឯវត្ថុប្រើសម្រាប់ចាក់ចេក ហៅថា "កាំបិតចាក់ចេក" ដែលជាដែកតូចយ៉ាងសាមញ្ញមួយ ដំច្នៃឱ្យសំប៉ែត មានមុខសងខាង សំលៀងឱ្យមុត ប្រវែងប្រហែល១ចំអាម ហើយភ្ជាប់នឹងដងសម្រាប់កាន់ (រូបលេខ១៤-១៥)។ ជា

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

ទូទៅមានពីរខ្នាត គឺកាំបិតខ្នាតតូចប្រើសម្រាប់វាលក្បាច់ និងកាំបិតខ្នាតធំប្រើសម្រាប់ចាក់ទម្រង់ធ្មេញត្រី។ ចំណែកកាំបិតតូចធម្មតាមួយទៀត ត្រូវសំលៀងឱ្យមុតល្អ គឺប្រើសម្រាប់ច្រៀក និងតម្រឹមស្រទបចេក។

ឯបច្ចេកទេសចាក់ឱ្យចេញជាក្បាច់ គឺមានលក្ខណៈពិសេសខ្លាំងណាស់ អ្នកចាក់ត្រូវតែរហ័ស ដ្បិតដើម្បីចាក់ឱ្យទាន់ និងចប់មុនពេលស្រទបចេកស្រពោនស្វិត។ ម្យ៉ាងទៀតគេត្រូវតែឈ្លាសក្នុងការប៉ាន់ប្រមាណប្រវែង ឬទម្រង់ក្បាច់ផ្សេងៗ ដើម្បីឱ្យក្បាច់ដែលចាក់ចេញហើយមានភាពរស់រវើក សមទាំងទំហំ សមទាំងប្រវែងសម្រាប់យកទៅតុបតែង។



រូបលេខ២១៤ កាំបិតចាក់ចេកខ្នាតតូច (រូប៖ អាន រស្មី)



រូបលេខ២១៥ បច្ចេកទេសចាក់ចេក (រូប៖ អាន រស្មី)

ស្រទបចេកដែលត្រូវចាក់ គឺត្រូវសម្អាតឱ្យស្អាត យកមកដាក់ផ្កាប់លើតុ ឬដាក់លើកន្ទេលផ្ទាល់ក៏បាន ដោយត្រួតគ្នាពីរជាន់ ឬមួយជាន់ ហើយអ្នកចាក់នឹងចាប់ផ្ដើមលៃប្រមាណទំហំ និងប្រវែងស្រទបចេកនោះ ហើយចាក់ខ្វាលឱ្យចេញជាក្បាច់យកភ្លាមៗតែម្ដង ពោលគឺពុំចាំបាច់គូរ ឬព្រាងអ្វីបន្តិចសោះឡើយ។ ស្រទបចេកដែលបានចាក់ចេញជាក្បាច់ភ្លឺរួចហើយ គេត្រូវផ្ដិះយកផ្នែក ឬផ្ទៃដែលពុំមែនជាសន្ទឹកក្បាច់ចេញ រួចផ្ដុំគ្របលើក្រដាសពណ៌ផ្សេងៗដូចជា ក្រហម លឿង ស្វាទុំ ផ្កាឈូក ឬបៃតង ដើម្បីរំលេចនូវក្បាច់លើស្រទបចេកនោះឱ្យលេចផុសឡើង។ បន្ទាប់មក គេយកក្បាច់បន្ទាប់បន្សំដូចជាធ្មេញរណា ធ្មេញក្របី ឬពងត្រី... ដោតភ្ជាប់នឹងគែមស្រទបចេកគោលដែលមានក្បាច់ស្រាប់ដូចនិយាយខាងលើ មុននឹងយកទៅដំឡើង ឬតុបតែងចងភ្ជាប់នឹងទីដែលត្រូវលម្អ(រូបលេខ២១៦-១៧)។

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត



រូបលេខ១៦ ការរៀបចំដំឡើងក្បាច់ចាក់ចេកបំពាក់តុបតែងលើទីសក្ការៈ



រូបលេខ១៧ ពុទ្ធបរិស័ទធ្វើកិច្ចនមស្ការមុខអស្នាព្រះលម្អដោយក្បាច់ចាក់ចេក

សរុបរួមមកគេសង្កេតឃើញថា ទម្រង់សិល្បៈក្បាច់រចនាសម្រាប់តុបតែងលម្អផ្នែកផ្សេងៗនៃសំណង់ ទីសក្ការៈ ឬប្រើលម្អកិច្ចនានាក្នុងវប្បធម៌ខ្មែរមានច្រើនសណ្ឋាន។ ក្បាច់ក្បូរខ្លះឆ្លាក់លើថ្ម ខ្លះលើឈើ ខ្លះលើលោហៈ ខ្លះធ្វើពីស៊ីម៉ងត៍... ហើយគង់វង្សរាប់ពាន់រាប់រយឆ្នាំ ប្រសិនបើមានការថែទាំត្រឹមត្រូវ។ ចំណែកក្បាច់រចនាសម្រាប់ប្រើលម្អមួយពេលខ្លី ឬឱ្យមើលឃើញស្អាតសមសួនមួយគ្រា គេច្រើនឆ្លាក់លើវត្ថុឆាប់ខូចទៅវិញ ទៅតាមកាលតាមធម្មជាតិវត្ថុនោះ ច្នៃទៅតាមគំនិតប្រាជ្ញារបស់មនុស្ស។ ឧទាហរណ៍ "ចាក់ចេក" ជាប្រភេទសិល្បៈមួយបែប ដែលចាក់ឆ្លាក់ធ្លាលធ្មៀលផ្ដឹះចេញពីស្រទបចេក ឱ្យកើតជាក្បាច់រចនាកាច់កោងពត់ពេនក្នុងទម្រង់ផ្សេងៗ សម្រាប់លម្អលើទីសក្ការៈក្នុងពិធីបុណ្យនានាប្រើត្រឹមមួយពេលខ្លីប៉ុណ្ណោះ។ បច្ចុប្បន្ន ទម្រង់សិល្បៈនេះហាក់កាន់តែហោចទៅ ហើយគេច្រើនប្រើជំនួសវត្ថុមានស្រាប់ ដដែលពីពេលមួយទៅពេលមួយ ដែលឥតមានលក្ខណៈសិល្បៈអ្វីសោះ៕

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

# ឯកសារពិគ្រោះ


ច័ន្ទ វិត្ថារិន

២០០៥, *ក្បាច់ខ្មែរ*, រៃឃំ, ភ្នំពេញ

ព្រាប ចាន់ម៉ារ៉ា

២០០៨, "ចាក់ចេក", *កម្រងអត្ថបទក្នុងបណ្ដាញព័ត៌មានវប្បធម៌ខ្មែរ*, ទំ. ៤៧-៥១, យសោធរ, ភ្នំពេញ

ព្រាប ចាន់ម៉ារ៉ា, គង់ វីរៈ និង ជី រដ្ឋា

២០១៣, *អំពីព្រះរាជពិធីបុណ្យថ្វាយព្រះភ្លើង*, ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ, ភ្នំពេញ

លឹម ស្រ៊ូ

២០១៧, "គ្រឿងរណ្ដាប់ ចាក់ចេក និងកាច់បាយសី" ផ្សាយលើគេហទំព័រ *https://thmeythmey.com/?page=detail&id=51975* ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៧


*អត្ថបទដោយ៖ ហៀន សុវណ្ណមរកត*